

# វេទិកាជាតលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ
# ព្រះរាជាណាចក្រកម្ពុជា
# ថ្ងៃទី០៣-០៥ ខែតុលា ឆ្នាំ២០១១

## ការឆ្ពោះទៅរកផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា

**លោក ស៊ុ ធី**

ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ
នៃគម្រោងគ្រប់គ្រងចំណេះដឹង និងអភិវឌ្ឍន៍គោលនយោបាយប្រែប្រួលអាកាសធាតុ
ក្រសួងបរិស្ថាន

# មាតិកា និងគោលបំណង នៃបទបង្ហាញ

- បទបង្ហាញនេះនឹងផ្តល់ នូវសារៈតា សនិទានភាព គោលបំណង និងមាតិកាព្រាង នៃផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) និងផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តន៍

## • គោលបំណង

- ធ្វើការណែនាំឲ្យដឹងពីទស្សនទាន CCCSP និងក្របខ័ណ្ឌគោលការណ៍ណែនាំ និងផែនទីបង្ហាញផ្លូវ CCCSP

# សេចក្ដីផ្ដើម

- ទោះបីជាគំនិតផ្ដួចផ្ដើមបាន និងកំពុងអនុវត្ត ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅទូទាំងប្រទេសក៏ដោយ ក៏ប្រទេសកម្ពុជាមិនទាន់មានគោលនយោបាយ ឬយុទ្ធសាស្រ្តថ្នាក់ជាតិមានលក្ខណៈទូលំទូលាយ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅឡើយ

- ការធ្វើ CCCSP ជាសមិទ្ធផលដ៏សំខាន់មួយ សម្រាប់សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

# សនិទានភាព សម្រាប់ CCCSP

- ការធ្វើ CCCSP គឺស្របគ្នានឹងអាទិភាពជាតិ ដែលមានបង្ហាញក្នុងបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ (NSDP)
- ការបង្កើត នូវ CCCSP គឺស្របគ្នានឹងការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងសេចក្តីសម្រេច របស់ COP ដែលពាក់ព័ន្ធ ដូចជាកម្មវិធីការងារ Nairobi ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀង Cancun
- តម្រូវការ នៃក្របខ័ណ្ឌ ជាមគ្គុទេស្ទក៍ សម្រាប់សម្របសម្រួលការងារអន្តរវិស័យ និងឱកាស សម្រាប់ការប្រែប្រួលអាកាសធាតុ

# CCCSP ជាឧបករណ៍សម្របសម្រួល សម្រាប់ របៀបវារៈប្រែប្រួលអាកាសធាតុ

- CCCSP នឹងជួយដល់កម្ពុជា និង NCCC ត្រៀមខ្លួន ចំពោះផលប៉ះពាល់ប្រែប្រួលអាកាសធាតុថ្នាក់តំបន់ និងសាកល និងជួយដល់កម្ពុជា ក្នុងការត្រៀមចាប់យកឱកាសឧបត្ថម្ភគាំទ្រជាសាកល សម្រាប់គំនិតផ្តួចផ្តើម ដែលចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍដោយចីរភាព

- ទន្ទឹមនឹងនេះ CCCSP នឹងផ្តល់នូវការណែនាំផ្លូវជាយុទ្ធសាស្ត្រអំពីវិធី ដែលកម្ពុជាអាចចូលរួមកាត់បន្ថយការបំភាយ ដែលជាការត្រួសត្រាយផ្លូវ សម្រាប់ការអភិវឌ្ឍកាបូនទាប និងការអភិវឌ្ឍបៃតង នៅទូទាំងប្រទេស

# ផែនទីបង្ហាញផ្លូវ សម្រាប់ CCCSP

- គោលការណ៍ណែនាំ សម្រាប់ CCCSP ធ្វើឡើង ដោយផ្អែកលើសេចក្តីប្រកាសលេខ ៩៣៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការរៀបចំ និងអភិវឌ្ឍន៍គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ហើយក្រុមការងារ CCCA ជាអ្នករៀបចំ CCCSP ព្រាង

- ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុបានធ្វើការពិនិត្យ និងអនុម័តលើ CCCSP ព្រាងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១

- NCCC បានអនុម័ត CCCSP ព្រាង នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ដោយមានការកែសម្រួលតិចតួច

# ទស្សនភាព CCCSP

- CCCSP នឹងរួមបញ្ចូល ប៉ុន្តែមិនកម្រិតត្រឹម ការធ្វើយុត្តិកម្ម និង គោលការណ៍ណែនាំសំខាន់ៗ
  - បញ្ជី នៃគ្រោះថ្នាក់/ហានិភ័យអាកាសធាតុ និងការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជា
  - ការឆ្លើយតបគោលនយោបាយប្រែប្រួលអាកាសធាតុ ដោយយោងតាមអាទិភាពប្រែប្រួលអាកាសធាតុ និងគោលជំហររបស់ប្រទេសកម្ពុជា និងការធ្វើឲ្យស៊ីសង្វាក់នឹងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ
  - យុទ្ធសាស្ត្រតាមវិស័យ សម្រាប់ការបន្សាំ ជាពិសេសផ្តោតជាសំខាន់លើវិស័យ និងអនុវិស័យអាទិភាព ដូចជាវិស័យកសិកម្ម ធនធានទឹក ជលផល រុក្ខកម្ម សុខភាពមនុស្ស តំបន់ឆ្នេរ ជីវចម្រុះ តំបន់ការពារ និងការឆ្លើយតបគោលនយោបាយសំខាន់ៗតាមបណ្តាវិស័យ

# ចក្ខុវិស័យ CCCSP (បន្ត)

- យុទ្ធសាស្ត្រកាត់បន្ថយ ពាក់ព័ន្ធនឹងវិស័យថាមពល និងមិនមែនថាមពល ដើម្បីឧបត្ថម្ភគាំទ្រដល់អភិវឌ្ឍន៍បៃតង
- យុទ្ធសាស្ត្រ ក្នុងការឆ្លើយតបនឹងផលប៉ះពាល់ប្រែប្រួលអាកាសធាតុ និងឱកាសប្រែប្រួលអាកាសធាតុ សម្រាប់អន្តរវិស័យ រួមមានការសម្របសម្រួល ការអភិវឌ្ឍស្ថាប័ន ការកសាងសមត្ថភាព ការលើកកម្ពស់ចំណេះដឹង សមភាពយេនឌ័រ សន្តិសុខស្បៀង ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការព្យាករណ៍ និងតាមដានធាតុអាកាស SN-D & D និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- យុទ្ធសាស្ត្រហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងយន្តការហិរញ្ញប្បទាន ដែលបានស្នើឡើង

# វិធានអនុវត្ត CCCSP

- ធ្វើការពិនិត្យ និងសំយោគឯកសារតាមវិស័យ និងថ្នាក់ជាតិដែលមាន ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- មានឯកភាពគ្នា រវាង NCCC លើចក្ខុវិស័យ បេសកកម្ម និង គោលបំណង CCCSP
- ធ្វើការកំណត់ នូវគោលជំហររបស់ប្រទេសកម្ពុជា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ក្នុងបរិបទការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពនិងការប្រើប្រាស់ដោយមានសនិទានភាព នៃធនធានធម្មជាតិ
- រៀបចំការវិភាគគោលនយោបាយប្រែប្រួលអាកាសធាតុតាមវិស័យ ក្នុងវិស័យសំខាន់ៗ ដោយមានការវិភាគភាពស៊ីសង្វាក់គ្នា នៃគោលនយោបាយប្រែប្រួលអាកាសធាតុ

# សេចក្តីសន្និដ្ឋាន / ជំហានបន្ទាប់

- ការបញ្ចូលបណ្តាវិស័យ ក្នុងការអភិវឌ្ឍ CCCSP ជាការងារសំខាន់ ក្នុងការកសាងការឆ្លើយតបប្រែប្រួលអាកាសធាតុដ៏រឹងមាំ និងភាពជាម្ចាស់ការតាមវិស័យ និងថ្នាក់ជាតិ នៃ CCCSP
- សកម្មភាពតាមវិស័យ CCCSP ចាប់ផ្តើមបន្ទាប់ពីវេទិកានេះ
- វិស័យអាទិភាព នៃ CCCSP ត្រូវមានការឯកភាពដោយផ្អែកលើការប្រឹក្សាជាមួយអ្នកពាក់ព័ន្ធ និងការអនុម័តរបស់ NCCC
  - វិស័យ ដែលជាវិស័យអាទិភាពដ៏សំខាន់របស់រដ្ឋាភិបាល
  - វិស័យ ដែលងាយទទួលរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ
  - វិស័យ ដែលឧបត្ថម្ភគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា

# សូមអរគុណ!



For more information:

*www.camclimate.org.kh*